ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌលេខ៣០៦ ចុះថ្ងៃទ២៩ ខែមេសា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ២៣៦ម.ខ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ៥៨២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១
កាលបរិច្ឆេទសវនាការថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២
សាលក្រមលេខ: [illegible] "ឈ"
ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

**<u>បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រះសីហនុ</u>**

**<u>ដោយមានសមាសភាពដូចតទៅ</u>**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៣០៦ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ លើជនជាប់ចោទដូចខាងក្រោម៖

ឈ្មោះ [redacted] SU ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិចិន មុខរបរលក់ដូរឥវ៉ាន់មួយទឹក កាន់លិខិតឆ្លងដែនលេខ [redacted] ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ មានទីកន្លែងនៅជាំងស៊ី ប្រទេសចិន មានទីលំនៅបច្ចុប្បន្ននៅសណ្ឋាគារជឹងស៊ា ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] សានតាន មានកូនចំនួន ០១នាក់ ឪពុកឈ្មោះ [redacted] អឹងហ័រ "ស" ម្តាយឈ្មោះ [redacted] ហាន់ជិន "ស" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុនមក "គ្មាន"។ (**ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៣៣ តព/២១ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១**)

ជាប់ចោទពីបទ **រារាំងដល់ការអនុវត្តវិធានការ** ប្រព្រឹត្តនៅក្រុមទី៧ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤ និងមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

អ្នកបកប្រែឈ្មោះ [redacted] **គីមហុង** ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្ននៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៥៨៣ អ.យ.គ/២១ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាដំណោះស្រាយលេខ៣៥៧៤ ត.៣/២១ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ៤២៦១ ត.ព.វ/២១ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ៤៨១៩ ត.ព.វ/២១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ៥៤៩៣ ត.ព.វ/២១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង២១ និង ០០នាទី នៅចំណុចគោលដៅបិទខ្ទប់ ស្តុបផ្សារពាណិជ្ជកម្ម ស្ថិតនៅក្រុមទី៧ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជនសង្ស័យឈ្មោះ [redacted] SU បានធ្វើសកម្មភាព ជិះម៉ូតូមួយគ្រឿង ម៉ាក អ៊ែប្លែក ពណ៌ខ្មៅ ផលិតឆ្នាំ២០២០ ពាក់ស្លាកលេខ កំពត 1J-9756 បុកប៉ារ៉ាសរត់គេចខ្លួន ភ្លាមនោះកម្លាំងយាមគោលដៅ នឹងកម្លាំងអធិការដ្ឋាននគរបាលខេត្តព្រះសីហនុ បានធ្វើការប្រដេញតាមរហូតដល់មុខសណ្ឋាគារ យ៉ាព័រ ទើបធ្វើការឃាត់ខ្លួនជនសង្ស័យបាន។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] SU បានឆ្លើយថា ៖ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដែលជាថ្ងៃកើតហេតុ វេលាប្រហែលម៉ោង០៨ ទៅម៉ោង ០៩យប់ ខ្លួនបានជិះម៉ូតូតាមផ្លូវជាតិលេខ៤ នៅផ្ទះ។ លុះនៅពេលនោះដែរខ្លួនបានផឹកស្រាបៀរអស់ចំនួន ០១កំប៉ុង ប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា គាត់ឈឺ នាពេលនោះខ្លួនក៏បានជិះម៉ូតូត្រលប់មកវិញ លុះមកដល់កន្លែងគោលដៅសមត្ថកិច្ច គេបានហៅខ្លួនឱ្យឈប់ តែនាពេលនោះខ្លួនមិនបានដឹងថា អ្នកណាហៅខ្លួនឱ្យឈប់នោះទេ ព្រោះមើលមិនច្បាស់ ទើបខ្លួនមិនបានឈប់ និងបានជិះម៉ូតូបន្តរហូតដល់ផ្លូវសេតេ ជិតដល់កាស៊ីណូ យ៉ាព័រ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ នៅពេលខ្លួនកំពុងជិះតាមផ្លូវ ខ្លួនមិនឃើញមានសមត្ថកិច្ចនោះទេ។ នៅថ្ងៃកើតហេតុ ខ្លួនបានផឹកនៅផ្ទះមិត្តភក្តិវេលាម៉ោង ០៦ល្ងាច ហើយនាពេលនោះខ្លួនមិនបានដឹងថា គេហាមមិនឱ្យផឹកគ្រឿងស្រវឹងឡើយ លុះពេលខ្លួនត្រលប់មកវិញមកដល់ចំណុចកំពង់ផែ ទើបសមត្ថកិច្ចបានហៅខ្លួន។ ខ្លួនមិនបានដឹងថា នៅពេលនោះនរណាជាអ្នកហៅខ្លួននោះទេ ព្រោះនាពេលនោះងងឹតមើលមិនឃើញ។ មូលហេតុដែលសមត្ថកិច្ចហៅខ្លួន ហើយខ្លួនមិនឈប់ ព្រោះនៅថ្ងៃកើតហេតុ ខ្លួនបានទទួលសារគំរាមជាច្រើនលើកច្រើនសារ ហើយនាពេលនោះមានករណីបង្ខាំងយ៉ាងច្រើន។ ខ្លួនពិតជាបានបុកខ្សែដែលគេបានចងនៅខាងមុខ ហើយនៅពេលបុកខ្សែនោះដែរ ទីតាំងនោះខ្លួនមើលមិនច្បាស់នោះទេ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ និងពិនិត្យភស្តុតាងនានាដែលមានក្នុងសំណុំរឿងរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] SU បានឆ្លើយថា ខ្លួនពិតជាបានបុកខ្សែរបស់សមត្ថកិច្ច តែមិនចាំម៉ោងនោះទេ ប៉ុន្តែបើតាមរបាយការណ៍របស់សមត្ថកិច្ចគឺនៅវេលាម៉ោង ០៩យប់ ហើយវិធានការរបស់រដ្ឋបាលខេត្ត គឺហាមមិនឱ្យមានការធ្វើដំណើរឡើយ។ ដែលសកម្មភាពខាងលើគឺជាអំពើល្មើស។ ហេតុដូច្នេះ តំណាងអយ្យការស្នើសុំរក្សាបទចោទដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៥៨៣ អ.យ.គ/២១ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុទុកជាបានការដដែល និងស្នើសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើតាមច្បាប់ជាធរមាន។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តី និងភស្តុតាងនានា ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនសូមបដិសេធនូវការចោទប្រកាន់របស់តំណាងអយ្យការ ដោយហេតុថា អង្គហេតុដែលបានកើតឡើង គឺកូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ហើយគាត់ជាជនជាតិចិន មិនបានដឹងឡើយ អំពីវិធានការរដ្ឋបាល។ ហើយនាពេលនោះដែរ ដោយកូនក្តីខ្លួនបានទទួលសារ គំរាមជាច្រើនលើកច្រើនសារ ទើប

មានការភ័យខ្លាច និងពុំបានរារាំងដល់ការអនុវត្តរបស់សមត្ថកិច្ចនោះទេ។ ហេតុនេះជារួមឃើញថា សកម្មភាពរបស់កូនក្តីខ្លួនគឺផ្ទុយទៅនឹងបញ្ញត្តិមាត្រា១០ មិនស្ថិតនៅក្នុងមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដូច្នេះខ្លួនស្នើសុំដល់ចៅក្រមជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ និងដោះលែងគាត់ឱ្យមានសេរីភាពវិញ។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] SU ៖ ស្នើសុំដល់តុលាការដោះលែងខ្លួនឱ្យមានសេរីភាពវិញ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សំគាល់របស់តំណាងអយ្យការប្តឹងសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ
## យល់ឃើញថា

**១.**ជនជាប់ចោទឈ្មោះ [redacted] SU បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុ ខ្លួនបានទៅផ្ទះមិត្តភក្តិ និងបានផឹកស្រាបៀរអស់ ០១កំប៉ុង លុះនៅវេលាប្រហែលម៉ោង០៨ ទៅម៉ោង ០៩យប់ ប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ថា គាត់ឈឺ ខ្លួនក៏បានជិះម៉ូតូមកវិញដល់កន្លែងគោលដៅសមត្ថកិច្ច គេបានហៅខ្លួនឱ្យឈប់តែខ្លួនមិនបានដឹងថា អ្នកណាហៅទេ ទើបខ្លួនមិនបានឈប់ និងបានជិះម៉ូតូបន្តរហូតដល់ផ្លូវសេតេ ជិតដល់កាស៊ីណូ យ៉ាព័រ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ នៅពេលខ្លួនកំពុងជិះតាមផ្លូវ ខ្លួនមិនឃើញមានសមត្ថកិច្ចនោះទេ និងមិនបានដឹងថា គេហាមមិនឱ្យផឹកគ្រឿងស្រវឹងឡើយ។ នៅពេលសមត្ថកិច្ចហៅខ្លួន ហើយខ្លួនមិនបានឈប់ ព្រោះនៅថ្ងៃកើតហេតុ ខ្លួនបានទទួលសារគំរាមជាច្រើនលើកច្រើនសារ។ ខ្លួនពិតជាបានបុកខ្សែដែលគេបានចងនៅខាងមុខ ហើយនៅពេលបុកខ្សែនោះដែរ ទីតាំងនោះខ្លួនមើលមិនច្បាស់នោះទេ។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើ គ្រាន់តែជាចម្លើយដែលឆ្លើយដោះសារដើម្បីគេចវេសពីការទទួលខុសត្រូវតែប៉ុណ្ណោះ ដោយមិនមានភស្តុតាង និងសាក្សីណាបញ្ជាក់ឱ្យតុលាការជឿជាក់បានឡើង ផ្ទុយមកវិញតាមចម្លើយជនជាប់ចោទដដែល បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច និងនៅដំណាក់កាលចៅក្រមស៊ើបសួរបានបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូពីផ្ទះមិត្តភក្តិនៅម្តុំឃ្លាំងលើ ដើម្បីទៅផ្ទះ លុះជិះដល់ចំណុចស្តុបផ្សារពាណិជ្ជកម្មក៏ជួបសមត្ថកិច្ចដាក់ប៉ារ៉ាស់ត្រួតពិនិត្យ ដោយសមត្ថកិច្ចមិនឱ្យខ្លួនទៅមុខ ខ្លួនក៏ជិះបត់ត្រលប់ក្រោយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ដែលចម្លើយត្រង់ចំណុចនេះមានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍លេខ ៩១/២១ រ.ប.ក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ។

**២.**តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយរបស់ជនជាប់ចោទ អាចបញ្ជាក់បានថា កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ២១ និង ០០នាទីយប់ ជនជាប់ចោទឈ្មោះ [redacted] SU ពិតជាបានធ្វើសកម្មភាពធ្វើដំណើរដោយគ្មានការអនុញ្ញាត ល្មើសនឹងបំរាមគោចរ ដែលជាសេចក្តីសម្រេចការបិទខ្ទប់របស់រដ្ឋបាលខេត្តព្រះសីហនុ និងបានជិះម៉ូតូបុកខ្សែប៉ារ៉ាស់របស់សមត្ថកិច្ច ដែលកំពុងឈរជើងអនុវត្តទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩។ ដែលអំពើរបស់ជនជាប់ចោទខាងលើត្រូវបានច្បាប់បញ្ញត្តិជាបទល្មើស **រារាំងដល់ការអនុវត្តវិធានការ** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤ និងមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត។

**៣.**អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] SU បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយ និងសុខភាពសាធារណៈធ្ងន់ធ្ងរ ហើយជនជាប់ចោទមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន គប្បីតុលាការពិចារណាពីការផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃក្រមព្រហ្មទណ្ឌ។

៤.មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] SU ពីបទ ៖ **រារាំងដល់ការអនុវត្តវិធានការ** ប្រព្រឹត្តនៅក្រុមទី៧ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤ និងមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីត-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

## <u>ហេតុដូច្នេះសម្រេច</u>

ផ្តន្ទាទោសឈ្មោះ [redacted] SU ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ខែ** ពីបទ ៖ **រារាំងដល់ការអនុវត្តវិធានការ** ប្រព្រឹត្តនៅក្រុមទី៧ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤ និងមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីត-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] SU ភេទប្រុស។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា ÷** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា ÷** [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥**
**ខេត្តព្រះសីហនុ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២**
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រម**

[redacted]